**សម្ភាសន៍ជាមួយ សួង ស៊ុន ភេទប្រុស អាយុ៦០ឆ្នាំ**

**រស់នៅភូមិកោះកេរ្តិ៍ ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ**

**មុខងារសម័យខ្មែរក្រហមៈ ពេទ្យស្រុកចុងកាល់**

**ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**០០:៣១:០៧**

**១៨ទំព័រ**

ដានីៈ បាទ លោកពូមុននឹងខ្ញុំចាប់ផ្តើមសួរនាំពីជីវិតផ្ទាល់ខ្លួនលោកពូ ខ្ញុំចង់ណែនាំខ្លួនខ្ញុំប្រាប់លោកពូមួយសារទៀត ខ្ញុំឈ្មោះដានី គាត់ឈ្មោះបងវណ្ណៈ ពួកខ្ញុំពីរនាក់នេះមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា នៅទីក្រុងភ្នំពេញ ពួកខ្ញុំនេះធ្វើការទាក់ទងនឹងការប្រមែលប្រមូលបងក្រងឯកសារទាក់ទងពីសម័យសង្គ្រាម ពីសម័យ៣ឆ្នាំ ពីឆ្នាំ១៩៧៥-១៩៧៩ សម័យប៉ាយរួម ហើយក្រោយមកសម័យសង្គ្រាម ជីវិតផ្ទាល់ខ្លួនរបស់លោកពូដែលបានឆ្លងកាត់មកតាំងពីតូចមក មួយដំណាក់ៗដល់ឥឡូវ សម័យយើងអភិវឌ្ឍន៍ក្រោយៗនេះ ហើយមុននឹងខ្ញុំចាប់ផ្តើមសួរនាំលោកពូ លោកពូមានអីចង់ ដូចថាឆ្ងល់ចង់សួរនាំខ្ញុំទេ ។

ស៊ុនៈ អត់មានឆ្ងល់អីទេ ។

ដានីៈ ដំបូងខ្ញុំចង់ស្គាល់ឈ្មោះលោកពូពេញ ឈ្មោះអីដែរ?

ស៊ុនៈ ឈ្មោះ សួង ស៊ុន ។

ដានីៈ បាទ?

ស៊ុនៈ សួង ស៊ុន ។

ដានីៈ ឈ្មោះ ដួង ស៊ុន?

ស៊ុនៈ សួង ។

ដានីៈ «ស» ដាក់ «្វ» និង «ង» ។

ស៊ុនៈ «ស» «៊» ។

ដានីៈ ស៊ុន?

ស៊ុនៈ បាទ ។

ដានីៈ លោកពូអាយុប៉ុន្មានហើយសព្វថ្ងៃ?

ស៊ុនៈ ខ្ញុំ៦០ ។

ដានីៈ ស្រុកកំណើតកើតជានៅភូមិ-ឃុំ ស្រុកអីដែរ?

ស៊ុនៈ ខ្ញុំកំណើតពីដើម ខ្ញុំនៅឃុំដំដែក ស្រុកសូទ្រនិគម ខេត្តសៀមរាប ។

ដានីៈ នៅភូមិអីគេដែរ?

ស៊ុនៈ នៅភូមិគោករលួស ។

ដានីៈ ភូមិគោក?

ស៊ុនៈ គោករលួស ។

ដានីៈ គោករលួស?

ស៊ុនៈ បាទ គោករលួស ។

ដានីៈ ឃុំ?

ស៊ុនៈ ឃុំដំដែក ។

ដានីៈ ស្រុក?

ស៊ុនៈ សូទ្រនិគម ។

ដានីៈ ខេត្តសៀមរាប?

ស៊ុនៈ បាទ ។

ដានីៈ សព្វថ្ងៃនេះនៅរស់នៅក្នុងភូមិ-ឃុំ ស្រុកអីដែរ?

ស៊ុនៈ ខ្ញុំនៅភូមិកោះកេរ្តិ៍ ។

ដានីៈ សព្វថ្ងៃនេះរស់នៅភូមិកោះកេរ្តិ៍?

ស៊ុនៈ បាទ ។

ដានីៈ កោះកេរ្តិ៍ ឃុំអីដែលនេះ?

ស៊ុនៈ ឃុំស្រយ៉ង់ ស្រុកគូលែន ។

ដានីៈ ស្រុកគូលែន?

ស៊ុនៈ ខេត្តព្រះវិហារ ។

ដានីៈ ខេត្តព្រះវិហារ?

ស៊ុនៈ បាទ ។

ដានីៈ លោកពូគ្រួសារលោកពូគាត់ឈ្មោះអីដែរ?

ស៊ុនៈ ឈ្មោះ ប្រិត យ៉ាន ។

ដានីៈ ឈ្មោះ?

ស៊ុនៈ ប្រិត យ៉ាត ។

ដានីៈ ប្រិត?

ស៊ុនៈ បាទ ។

ដានីៈ “ច” ជើង “រ” “ ិ” និង “ត”?

ស៊ុនៈ បាទ ។

ដានីៈ ច្រិត យាន, “យ” “ ៉” “ា” និង “ន”?

ស៊ុនៈ នោះហើយ ។

ដានីៈ ច្រិត យ៉ាន គាត់អាយុប៉ុន្មានហើយ?

ស៊ុនៈ អាយុ៥៨ឆ្នាំ ។

ដានីៈ គាត់អ្នកស្រុកកំណើតកើតជានៅណាដែរ?

ស៊ុនៈ ដែលកើតៗ នៅខាងដំដែកហ្នឹងទេ តែមកបានប្រពន្ធនៅភូមិកោះកេរ្តិ៍ ។

ដានីៈ តែប្រពន្ធលោកពូស្រុកកំណើត?

ស៊ុនៈ កំណើតនៅនេះ ប្រាកដប្រជានៅនេះ ។

ដានីៈ កំណើតនៅភូមិកោះកេរ្តិ៍?

ស៊ុនៈ បាទ ។

ដានីៈ លោកពូមានកូនចៅប៉ុន្មាននាក់ដែរ?

ស៊ុនៈ កូនរាប់ទាំងបានគ្រួសារ?

ដានីៈ ទាំងអស់ កូនចៅប៉ុន្មាននាក់?

ស៊ុនៈ ចេះលោកគ្រូខ្ញុំសុំទោស ខ្ញុំប្តីចុងទេ ជាប្តីចុងរបស់គាត់ទេ ទើបតែបានគាត់ប្រហែល៣-៤ឆ្នាំ ហើយសុទ្ធតែកូនចាស់គាត់ដាក់ដែរ?

ដានីៈ បាទ ។

ស៊ុនៈ កូនដើមគាត់ដាក់ដែរ?

ដានីៈ តែអ៊ំអត់មានកូនជាមួយគាត់ទេ?

ស៊ុនៈ អត់ទេ អត់ទាន់មានទេ កូនដើមគាត់ កូនប្តីគាត់ដើម ។

ដានីៈ ប៉ុន្មាននាក់ទៅ?

ស៊ុនៈ នៅក្នុងបន្ទុកគ្រួសារខ្ញុំ វាប្រុស២ ស្រី១ ។

ដានីៈ ប្រុស២ ស្រី១?

ស៊ុនៈ បាទ ។

ដានីៈ លោកពូកាលពីក្មេងៗលោកពូបានរៀនសូត្រដល់ណាដែរ?

ស៊ុនៈ ខ្ញុំបួស ។

ដានី៖ កាលពីក្មេងបួស?

ស៊ុន៖ បាទ បួសបាន២វស្សា ។

ដានី៖ បួសបាន២វស្សា?

ស៊ុន៖ បាទ ។

ដានី៖ បួសនៅណាទៅ?

ស៊ុន៖ ខ្ញុំបួសនៅវត្តព្រហ្មច័ន្ទ ។

ដានី៖ នៅវត្តព្រហ្មច័ន្ទ?

ស៊ុន៖ បាទ ។

ដានី៖ ហ្នឹងនៅក្នុងភូមិគោករលួសដែរ?

ស៊ុន៖ បាទ ។

ដានី៖ ដល់ពេលបន្ទាប់ពីបួស២ឆ្នាំហើយធ្វើអីទៀតទៅ?

ស៊ុន៖ ខ្ញុំសឹកមកសង្គ្រាមតែម្តង ។

ដានី៖ សង្គ្រាមឆ្នាំប៉ុន្មាន សឹកឆ្នាំណា?

ស៊ុន៖ ឆ្នាំ៧០គត់ ។

ដានី៖ ធ្វើអីទៅដល់ពេលសង្គ្រាម?

ស៊ុន៖ សង្គ្រាមទៅក៏ខ្ញុំសឹកពីបួសមក ខ្ញុំចូលធ្វើជាកងឈ្លបឲ្យគេ ធ្វើឈ្លបទ័ពខ្មែរក្រហមការពារគេ ការពារគេអ្នកធំៗ ។

ដានី៖ តាំងពីឆ្នាំ៧០?

ស៊ុន៖ បាទ ។

ដានី៖ ធ្វើឈ្លបការពារឲ្យពីណាខ្លះដែរ?

ស៊ុន៖ ឲ្យមេសហករណ៍ដែលគេជាអ្នកដឹកនាំ ។

ដានី៖ ធ្វើឈ្លបនៅក្នុងភូមិកំណើតដដែល ឬក៏មាននៅណា?

ស៊ុន៖ នៅក្នុងឃុំដដែល ។

ដានី៖ ក្នុងឃុំដីដែកហ្នឹង?

ស៊ុន៖ បាទ ។

ដានី៖ ធ្វើឈ្លបនៅក្នុងឃុំដីដែក នៅដីដែកហ្នឹងតាំងពីឆ្នាំ៧០មកខ្មែរក្រហមគេគ្រប់គ្រងរហូត?

ស៊ុន៖ បាទ គ្រប់គ្រងរហូតមែនអត់ដែលមានបានសម័យលន់ នល់ យើងនៅទេ ។

ដានី៖ អត់មានលន់ នល់ អីមក?

ស៊ុនៈ វៃដាច់យូរហើយ រំដោះបានយូរហើយតាំងពីសម័យ៧០ ។

ដានីៈ តាំងពីឆ្នាំ៧០មក?

ស៊ុនៈ វាទៅប្រទាញប្រទង់ តែវារំដោះបាន ពួកយួនវៃរំដោះទៅនៅតែសៀមរាប ផ្លូវជាតិលេខ ៦ យើងដាច់កាលហ្នឹង ។

ដានីៈ ចុះឪពុកម្តាយលោកពូ?

ស៊ុនៈ ឪពុកម្តាយខ្ញុំស្លាប់អស់ ។

ដានីៈ ស្លាប់តាំងពីឆ្នាំណាទៅ?

ស៊ុនៈ ស្លាប់យូរហើយ សម័យ៧២ ។

ដានីៈ យូរហើយ ទាំងឪពុក ទាំងម្តាយ?

ស៊ុនៈ បាទ ស្លាប់ចោល ។

ដានីៈ ឪពុកឈ្មោះអីទៅលោកពូ?

ស៊ុនៈ ឈ្មោះ ឡាញ់ ។

ដានីៈ ឈ្មោះ ឡាញ់?

ស៊ុនៈ សួង ឡាញ់ ជីតាខ្ញុំសួង ។

ដានីៈ ចុះម្តាយ?

ស៊ុនៈ ម្តាយ ម៉ក់ វ៉ាន់ ។

ដានីៈ គាត់ខូចឆ្នាំណាដែរ?

ស៊ុនៈ គាត់ខូចបន្តបន្ទាប់គ្នា លោកគ្រូ ៧៣សម័យដែលខ្មែរក្រហមវៃជាមួយយួន ជាមួយវៀតណាម ។

ដានីៈ បងប្អូនប៉ុន្មាននាក់ដែលលោកពូ?

ស៊ុនៈ បងប្អូនខ្ញុំ៦នាក់ ។

ដានីៈ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ស៊ុនៈ ស្រី២ ប្រុស៤ ។

ដានីៈ លោកពូកូនទីប៉ុន្មាន?

ស៊ុនៈ ខ្ញុំចុងពៅគេបង្អស់ ។

ដានីៈ តាំងពីឆ្នាំ៧០មកលោកពូធ្វើឈ្លប?

ស៊ុនៈ បាទ ។

ដានីៈ ធ្វើឈ្លបហ្នឹងកាលហ្នឹងមានប្រពន្ធនៅ?

ស៊ុនៈ នៅទេ នៅលីវ អាយុ២០គាត់ ។

ដានីៈ ដល់ឆ្នាំណាបានយកប្រពន្ធ?

ស៊ុនៈ ខ្ញុំយក៧៦ ខែ២ ឆាប់បាន ។

ដានីៈ ខែ២ ឆ្នាំ៧៦?

ស៊ុនៈ បាទ ។

ដានីៈ អ៊ីចឹងលោកពូដល់ពេលឆ្នាំ៧៥ ពេលដែលខ្មែរក្រហមគេឈ្នះទូទាំងប្រទេស ឆ្នាំ៧៥ហ្នឹង លោកពូធ្វើអីទៀតទៅ?

ស៊ុនៈ ខ្ញុំគេឲ្យនៅខាងពេទ្យ នៅខាងពេទ្យវិញ ។

ដានីៈ ពេទ្យរបស់អីគេ?

ស៊ុនៈ ពេទ្យស្រុក ។

ដានីៈ ស្រុកអីគេ?

ស៊ុនៈ ពេទ្យស្រុកចុងកាល់ ។

ដានីៈ ទៅចុងកាល់វិញ?

ស៊ុនៈ បាទ ទៅខាងឧត្តរមានជ័យ ។

ដានីៈ អ៊ីចឹងពេលបែក៧៥ធ្វើពេទ្យតែម្ដង ឬធ្វើមុនហ្នឹងទៀត?

ស៊ុនៈ ធ្វើសង្គ្រាមរំដោះ ១៧ មេសារួច ។

ដានីៈ រំដោះ១៧ មេសា ហើយ?

ស៊ុនៈ បាទ និយាយហ្នឹងច្រលំ ។

ដានីៈ អ៊ីចឹងចន្លោះពី៧០-៧៥ធ្វើឈ្លប?

ស៊ុនៈ បាទ ។

ដានីៈ ធ្វើឈ្លបហ្នឹងនៅជិតដែករហូតដល់ពេលរំដោះ?

ស៊ុនៈ ធ្វើឈ្លបអត់បានរហូតទេ ធ្វើបានតែ១-២ខែខ្ញុំទៅសមរភូមិមុខ ទៅវៃខ្ញុំរបួសសព្វថ្ងៃខ្ញុំពិការ ត្រូវគ្រាប់ផ្លោងរបស់ទាហានលន់ នល់ ។

ដានីៈ ទៅសមរភូមិមុខនៅណាទៅសមរភូមិ?

ស៊ុនៈ សមរភូមិយើងមួយផ្លូវជាតិលេខ៦នេះ ពុះល្អុង ស្រុកក្រឡាញ់ ។

ដានីៈ ខាងកងអីគេទៅហ្នឹង?

ស៊ុនៈ ខាងកងទ័ពស្រុក ។

ដានីៈ ស្រុករបស់?

ស៊ុនៈ របស់ស្រុកក្រឡាញ់ ។

ដានីៈ ចេញពីសូទ្រនិគមវិញ ។

ស៊ុនៈ បាទ ចេញពីសូទ្រនិគមហើយ ។

ដានីៈ ចេញពីសូទ្រនិគម ទៅស្រុកក្រឡាញ់វិញ?

ស៊ុនៈ បាទ ។

ដានីៈ នៅស្រុកក្រឡាញ់រយៈពេលប៉ុន្មានទៅ?

ស៊ុនៈ ខ្ញុំនៅរយៈទាល់តែរំដោះដូចខ្ញុំជំរាបលោកគ្រូខាងដើម រំដោះ១៧ មេសា ទៅ បានគេបញ្ជូនខ្ញុំទៅនៅខាងស្រុកចុងកាល់ ។

ដានីៈ កាលហ្នឹងលោកពូទៅធ្វើពេទ្យវិញ កាលហ្នឹងយើងបានរៀនពេទ្យអត់?

ស៊ុនៈ រៀនដែលលោកគ្រូ តែខ្ញុំកំរិតវិជ្ជាទាប ក៏ធ្វើអត់កើតទេសព្វថ្ងៃ ធ្វើអត់កើត ។

ដានីៈ ប៉ុន្តែកាល៧៥ធ្វើកើត?

ស៊ុនៈ ធ្វើកើតតិចៗ គេណែនាំឲ្យ គេបកស្រាយឲ្យ ខ្ញុំចេះតែប្រើថ្នាំ ។

ដានីៈ លោកពូមិនមែនធ្វើប្រធានពេទ្យស្រុកទេ?

ស៊ុនៈ អត់ទេ ខ្ញុំវង សមាជិកគេទេ ប្រធានគេចាប់យកទៅអស់ហើយ ។

ដានីៈ កាលហ្នឹងប្រធាន អនុប្រធានគេចាប់ នៅលោកពូសមាជិក?

ស៊ុនៈ បាទ ។

ដានីៈ សមាជិកពេទ្យស្រុក?

ស៊ុនៈ ខ្ញុំកាលហ្នឹងជំនួយការឲ្យគេទេ មិនបានពេញសិទ្ធិជាកម្មាភិបាលនឹងគេទេ គ្រាន់តែជំនួយការខ្ញុំជាបុគ្គលិកសំរាប់ដើរព្យាបាល ហើយនឹងការបាញ់ថ្នាំនៅតាមភូមិ បាញ់ថ្នាំមូសការពារតាមសហករណ៍ តាមប្រជាពលរដ្ឋ ចែកជូនថ្នាំសន្លូវតាមប្រជាពលរដ្ឋតាមភូមិ តាមសហករណ៍តាមកងចល័ត ។

ដានីៈ ព្យាបាលតិចៗ?

ស៊ុនៈ បាទ ព្យាបាលតិចៗ ។

ដានីៈ ព្យាបាលប្រជាជន អីព្យាបាលកម្មាភិបាល?

ស៊ុនៈ កម្មាភិបាលផង ប្រជាជនផង ។

ដានីៈ កាលហ្នឹងលោកពូនៅពេទ្យស្រុកហ្នឹងរហូតដល់បែកឆ្នាំ៧៩ ឬក៏មានផ្លាស់អីទៅណាទៀត?

ស៊ុនៈ ៧៩បានខ្ញុំបានបកមកនៅខាងស្រុកកំណើតខ្ញុំដីដែកនេះវិញ ។

ដានីៈ បានស្រុកកំណើតដីដែកវិញ?

ស៊ិនៈ	បាទ ។

ដានីៈ	ប៉ុន្តែពីឆ្នាំ៧៥-៧៩ នៅអង្គភាពពេទ្យហ្នឹងរហូត?

ស៊ិនៈ	បាទ ទល់រំដោះ ខ្ញុំនៅ អ៊ូ! សុំទោសវាភ្លេច ខុសមួយចំណុចខ្ញុំដកខ្លួនផុតមកគេឲ្យខ្ញុំទៅនៅលុតដីខាងបិទភ្លឺ ទំនប់ ប្រឡាយ ហើយហ្នឹកហ្នើនការហូបចុកអត់ឃ្លានខ្លាំងបំផុត ។

ដានីៈ	ឆ្នាំណា?

ស៊ិនៈ	ឆ្នាំ៧៧ កាលហ្នឹងកំពុងលំបាក ប្រទាញប្រទង់ ។

ដានីៈ	៧៧ គេដកមកនៅណាវិញ?

ស៊ិនៈ	នៅតាមសហករណ៍ ខាងលើកប្រព័ន្ធភ្លឺស្រែ ។

ដានីៈ	សហករណ៍នៅណាទៅ?

ស៊ិនៈ	សហករណ៍នៅខាងចុងកាល់នេះលោកគ្រូ បានវៀតណាមចូលមកបានខ្ញុំនាំប្រពន្ធកូនខ្ញុំមកនៅខាងស្រុកកំណើតនេះវិញ ។

ដានីៈ	នៅរហូតដល់៧៩?

ស៊ិនៈ	បាទ ។

ដានីៈ	កាលហ្នឹងដល់គេដកឲ្យមកលុតដី ឲ្យមកធ្វើស្រែលំបាកទេ?

ស៊ិនៈ	លំបាក ។

ដានីៈ	ហូបចុក?

ស៊ិនៈ	អត់បាយ លំបាកវេទនានឹងការអត់បាយហូប ខ្ញុំខូចក្រពះដល់សព្វថ្ងៃ ដើមល្ហុង កំពីងបេកក៏ខ្ញុំហូបអស់ ។

ដានីៈ	ចុះការងាររលំបាកអត់?

ស៊ិនៈ	ការងារក៏លំបាកដែលលោកគ្រូ ម៉ោង៨ដល់ម៉ោង១១បានបាយ ព្រឹកឡើងគេមិនដែលឲ្យហូបស្រស់ស្រូបទេ ហើយដីឡូងដាំខ្លួនឯងក៏អត់មានហ៊ានដឹកហូបទេទាល់តែប្រាប់គេបានអាចដឹកបានហូប ការលំបាកនិងការឆ្លងកាត់សឹងតែមិនរស់ ។

ដានីៈ	លោកពូរៀបការតាំងពីឆ្នាំ៧៦?

ស៊ិនៈ	បាទ ។

ដានីៈ	ហើយប្រពន្ធលោកពូគាត់នៅខាងណាដែរ?

ស៊ិនៈ	ប្រពន្ធខ្ញុំនៅដីដែក ប្រពន្ធដើមទេលោកគ្រូ ។

ដានីៈ	ប្រពន្ធដើមនៅដីដែក ។

ស៊ិនៈ	ប្រពន្ធដើមខ្ញុំនៅដីដែក ស្រុកកំណើត ។

ដានី៖ ស្រុកកំណើតនៅដំដែក?

ស៊ុន៖ បាទ ។

ដានី៖ រៀបការឆ្នាំ៧៦ពេលលោកពូទៅចុងកាល់ហើយ?

ស៊ុន៖ បាទ ។

ដានី៖ ចុងកាលហើយ ប្រពន្ធពូនៅណា បានទៅរៀបការនៅ?

ស៊ុន៖ ប្រពន្ធខ្ញុំទៅនោះដែរ ទៅជួប ។

ដានី៖ ទៅជាមួយគ្នា?

ស៊ុន៖ គេបញ្ជូនទៅ ។

ដានី៖ គាត់ធ្វើអី?

ស៊ុន៖ ប្រពន្ធខ្ញុំក៏បញ្ចូលនៅក្នុងក្រសួងពេទ្យដែរ ។

ដានី៖ ហើយក៏រៀបការទៅ?

ស៊ុន៖ បាទ ។

ដានី៖ លោកពូមានកូនប៉ុន្មានកូនដើម?

ស៊ុន៖ កូន៦ ។

ដានី៖ ហើយដល់ពេលឆ្នាំ៧៩ត្រឡប់មកនៅដំដែកវិញ?

ស៊ុន៖ បាទ ។

ដានី៖ លោកពូកាលនៅចុងកាល់ កាលហ្នឹងក្នុងស្រុកចុងកាល់ហើយក្នុងតំបន់ប៉ុន្មានទៅ?

ស៊ុន៖ ឃុំគេលោកគ្រូ?

ដានី៖ ខេត្ត?

ស៊ុន៖ ខេត្តនៅខាងឧត្តរមានជ័យ ។

ដានី៖ ខេត្តឧត្តរមានជ័យគេហៅតំបន់ប៉ុន្មានទៅឧត្តរមានជ័យ?

ស៊ុន៖ តំបន់កាលហ្នឹងដូចជាតំបន់៣៥, តំបន់៣៤ទេខ្ញុំភ្លេចបាត់ទៅ ។

ដានី៖ មិនមែនតំបន់១០៦ទេ?

ស៊ុន៖ បាទ គេដាក់តំបន់១០៦ទេដឹងកាលសម័យភូមិភាគឧត្តរយើងខ្ញុំភ្លេចទៅ ភូមិភាគ៤ទេដឹង អ្ហូ! មិនមែនទេភូមិភាគ៣៥កាលនោះ តំបន់៣៥ ។

ដានី៖ តំបន់៣៥ ពីណាគេគណៈតំបន់?

ស៊ុន៖ គណៈតំបន់មានតាសុត, តាសៀន ។

ដានី៖ តាសុត, តាសៀន ។

ស៊ុនៈ ដកទៅអស់ហើយកម្មាភិបាលកាលហ្នឹង ។

ដានីៈ ដល់ពេលផុតគេដកតាសុត, តាសៀន ពីណាទៀតទៅ?

ស៊ុនៈ ពួកនីរតីមក កាលនោះឯងចំណាប់ណាស់ ខ្ញុំស្រមៃកាលនោះវេទនាចង់ងាប់ ។

ដានីៈ ដល់ពេលពួកនីរតីមកវេទនាតែម្តង?

ស៊ុនៈ វេទនាណាស់ និយាយពីប្រជាពលរដ្ឋយកទៅសម្លាប់គ្នាចោលខ្ញុំឃើញទាំងខ្សែៗ លោកអើយកាលនោះព្រឺ ។

ដានីៈ ពួកនីរតីមកពីណាមានស្គាល់ឈ្មោះគាត់?

ស៊ុនៈ ឈ្មោះ ឆឹង គណៈស្រុក ។

ដានីៈ គណៈស្រុក ឈ្មោះ ឆឹង?

ស៊ុនៈ បាទ អត់មានចេះអក្សរសាស្ត្រតិចទេកាលនោះ ។

ដានីៈ ឆឹង គណៈស្រុកចុងកាល់?

ស៊ុនៈ បាទ ។

ដានីៈ ចុះកាលពីមុនជំនាន់តាសុត, តាសៀន ?

ស៊ុនៈ តាណូន ។

ដានីៈ ឈ្មោះ នៅ?

ស៊ុនៈ ណូន មិនមែន នៅទេៗ «ណ» « ូ » និង «ន» ណូន ហ្នឹងនិស្សិតគាត់គណៈស្រុកនិស្សិតដែរ តាណូន អ៊ូ! សាស្ត្រាចារ្យមិនមែន និស្សិតទេ ដល់ធ្លាក់សម័យនីរតីមកបានដកគាត់ចេញ យកទៅសម្លាប់ចោលអស់ ។

ដានីៈ ដល់ពេលគណៈតំបន់បន្ទាប់ពី តាសុត, តាសៀន គេដកទៅ ខាងនីរតីចូលមកឈ្មោះអីវិញទៅ?

ស៊ុនៈ ធុច គណៈតំបន់ប្រចាំការនៅសៀមរាបភូមិភាគឧត្តរយើង ។

ដានីៈ ឈ្មោះ តាធុច?

ស៊ុនៈ បាទ តែខ្ញុំមិនដែលបានឃើញទេ ខ្ញុំនៅតូច ។

ដានីៈ ដែលលឺឈ្មោះ តាសែ អីអត់?

ស៊ុនៈ លឺតាសែ ។

ដានីៈ តាសែ ជំនាន់?

ស៊ុនៈ	តាសែ ជំនាន់មុន តាសែ ជំនាន់ក្រោយទេ មិនមែនជំនាន់ តាសុត, តាសៀន, តាសែ គាត់ប្រជុំថា ឲ្យប្រជាពលរដ្ឋរស់សប្បាយរីករាយវិញ ដល់ភូមិភាគនីរតីពីបទៅបាត់តាសែ ទៅបាត់ ឈ្មោះតាសែ ហ្នឹងខ្ញុំស្គាល់។

ដានីៈ	តាម៉ុច ហ្នឹងមកក្រោយ តាសែ ទៀត?

ស៊ុនៈ	តាម៉ុច មុនតាសែ។ តាសែ គ្នាគាត់តាំ ខ្សែបណ្តោយរបស់គាត់ ប្រធាន អនុប្រធានរបស់គាត់។

ដានីៈ	លោកពូថាលំបាកពួកនីរតីមកគ្រប់គ្រង ដែលថាសម្លាប់ច្រើនហ្នឹង គណៈតំបន់ឈ្មោះអីទៅចឹង?

ស៊ុនៈ	គណៈតំបន់ តាម៉ុចហ្នឹង។

ដានីៈ	តាម៉ុច ហ្នឹងគាត់អ្នកនីរតី ឬក៏អ្នកណា?

ស៊ុនៈ	អ្នកនីរតី។

ដានីៈ	តាម៉ុច ហ្នឹងដែលចាប់មនុស្សសម្លាប់ច្រើនអីហ្នឹង?

ស៊ុនៈ	បាទ។ កាលនោះសិត ដូចមិនមែនតាម៉ុច ឲ្យសម្លាប់ក៏មិនដឹង វាសម្លាប់គណៈស្រុកខ្លួនវាក៏មិនដឹង ប្រល័យពូជសាសន៍មែនទែន។

ដានីៈ	ដល់ពេល៧៩ហើយលោកពូមកដំដែកវិញ?

ស៊ុនៈ	បាទ។

ដានីៈ	ដំដែកមកធ្វើអីវិញទៅ?

ស៊ុនៈ	ដំដែកមកក៏ខ្ញុំធ្វើប្រធានយោធាឃុំដំដែក ខ្ញុំវៃជាមួយខ្មែរក្រហម ដែលវៀតណាមដកថយ

ដានីៈ	កាលហ្នឹងធ្វើប្រធានយោធាឃុំ?

ស៊ុនៈ	បាទ ចូលសារថ្មីម្តងទៀត ហ្នឹងចូលសារ។

ដានីៈ	ខាងជាមួយរាជរដ្ឋាភិបាល?

ស៊ុនៈ	រដ្ឋាភិបាលយើង ខាងនាយករដ្ឋមន្ត្រីហ៊ុនសែនយើង។

ដានីៈ	ធ្វើបានរយៈពេលប៉ុន្មានទៅ?

ស៊ុនៈ	ខ្ញុំធ្វើបានចំនួន៣ឆ្នាំទៅ បានរួបរួមគ្នាបានដកចេញ ដកហូតអាវុធអស់។

ដានីៈ	ឆ្នាំណា?

ស៊ុនៈ	ឆ្នាំ៨៥។

ដានីៈ	ឆ្នាំ៨៥?

ស៊ុនៈ	បាទ ដែលប្រមូលអាវុធបានអស់៨៥យើង។

ដានី៖ ដល់ឆ្នាំ៨៥ ម៉េចទៅ ដកទៅណាវិញ?

ស៊ុន៖ ខ្ញុំដកមកនៅប្រជាពលរដ្ឋយើងធម្មតា ធ្វើស្រែចំការតាមធម្មតា ។

ដានី៖ ឈប់ធ្វើវិញ?

ស៊ុន៖ បាទ ឈប់ធ្វើអីទាំងអស់ហើយ ធ្វើស្រែចំការរហូតដល់សព្វថ្ងៃនេះ ។

ដានី៖ ធ្វើស្រែ ធ្វើចំការរហូតដល់ឆ្នាំណាបានមកនៅកោះកេរ្តិ៍?

ស៊ុន៖ ខ្ញុំធ្វើស្រែបានប្រហែលជា៣-៤ឆ្នាំក៏ខ្ញុំ ខ្ញុំឈប់នឹងផ្តាច់ខ្លួនក៏បែកមកនេះ ។

ដានី៖ ផ្តាច់ខ្លួនឆ្នាំណា?

ស៊ុន៖ ផ្តាច់ខ្លួនកាលជំនាន់រួបរួមគ្នាដកអាវុធទៅខ្ញុំមកនេះឯង បានធ្វើស្រែ ។

ដានី៖ លោកពូថាពីឆ្នាំ៧៩ លោកពូមកពីចុងកាលមកនៅដីដែកធ្វើជាប្រធានយោធាឃុំ?

ស៊ុន៖ បាទ ។

ដានី៖ ធ្វើប្រធានយោធាឃុំកាលហ្នឹងយើងនៅជាមួយខ្មែរក្រហម?

ស៊ុន៖ បាទ ។

ដានី៖ នៅខ្មែរក្រហមដល់ឆ្នាំ៨៥ លោកពូឈប់ធ្វើប្រធានយោធាឃុំ?

ស៊ុន៖ បាទ ឈប់ហើយ ។

ដានី៖ ដល់ពេលឈប់ឆ្នាំ៨៥មក ធ្វើស្រែចំការប្រជាពលរដ្ឋធម្មតា?

ស៊ុន៖ ធ្វើស្រែចំការ ប្រជាពលរដ្ឋធម្មតា ។

ដានី៖ នៅដីដែកហ្នឹង?

ស៊ុន៖ បាទ នៅដីដែក ។

ដានី៖ នៅដីដែកបានប៉ុន្មានឆ្នាំ?

ស៊ុន៖ រយៈបាន១ឆ្នាំបានខ្ញុំមករកទិញដីនៅនេះ ។

ដានី៖ មកទិញដីនៅណា?

ស៊ុន៖ ទិញដីកោះកេរ្តិ៍នេះឯង ។

ដានី៖ អីចឹងទាំងប្រពន្ធ ទាំងកូនមកនៅកោះកេរ្តិ៍?

ស៊ុន៖ បាទ ប្រពន្ធដើមខ្ញុំស្លាប់ហើយ ដូចជំរាបលោកគ្រូខាងដើម ។

ដានី៖ ដល់ពេលឆ្នាំ៨៦មកនៅកោះកេរ្តិ៍?

ស៊ុន៖ បាទ ។

ដានី៖ កាលហ្នឹងមកនៅកោះកេរ្តិ៍ធ្វើអីទៅ?

ស៊ុន៖ ខ្ញុំធ្វើតែស្រែទេលោកគ្រូ រហូតដល់សព្វថ្ងៃនេះ ។

ដានី: មកនៅកោះកេត្តិធ្មើស្រែ មកនៅបានរយៈពេលប៉ុន្មានបានមានបញ្ហាអីដូចថា មានសង្គ្រាមទៀតដែលអត់ពីឆ្នាំ៧៩?

ស៊ុន: អត់ដែលមានសង្គ្រាមទេ សុខសប្បាយរហូតដល់សព្វថ្ងៃ។

ដានី: អីចឹងលោកពូនៅកោះកេត្តិរហូតដល់ឥឡូវហ្នឹងតែម្តង?

ស៊ុន: បាទ។

ដានី: អត់មានជម្លៀសទៅណាមកណាទេ?

ស៊ុន: អត់មានទៅណាទេ។

ដានី: ចុះពេលគេវៃគ្នា?

ស៊ុន: អត់ដែលវៃគ្នាទៀតទេចប់ត្រឹមហ្នឹង។

ដានី: ឆ្នាំ៨៨អី?

ស៊ុន: ៨៨ផ្តាច់គ្នាអស់ហើយ។

ដានី: អត់មានសង្គ្រាម អត់មានគេជម្លៀសទៅខាង?

ស៊ុន: បាទ អត់។

ដានី: ដូចថាទៅខាងព្រះវិហារ អត់មានជម្លៀស អត់មានអី?

ស៊ុន: ខាងប្រពន្ធខ្ញុំទៅ តែខ្ញុំអត់ដែលទេ ខ្ញុំមកនៅកោះកេត្តិតែម្តង ឯករាជ្យស្រេចតែម្តង អត់ដែលសង្គ្រាមទេ។

ដានី: អីចឹងឆ្នាំ៨៦មកនៅកោះកេត្តិរហូតអត់មានដែលទៅណាទេ?

ស៊ុន: អត់។

ដានី: ខាងខ្មែរក្រហមអត់ដែលចូលមកទេ?

ស៊ុន: ចូលមកតាំ ចូលមកម្តងមួយយាម។

ដានី: ខ្មែរក្រហមចូលមកម្តងមួយយាម មកយ៉ាងម៉េចដែរ លោកពូអាចរៀបរាប់ កាលលោកពូមក នៅឆ្នាំដំបូង ឆ្នាំ៨៦?

ស៊ុន: មករកអីហូបនេះឯង សុំអង្ករហូប។

ដានី: ខ្មែរក្រហមចូលមកគេមកសុំអង្ករ សុំអីដែរ?

ស៊ុន: បាទ ជាបង ជាប្អូនចែកអីហូប។

ដានី: កាលហ្នឹងខ្មែរក្រហមគេនៅខាងកងពលណាដែលគេចូលមកឆ្នាំ៨៦ ហើយនឹងក្រោយមក?

ស៊ុន: ខាងតាម៉ុកហ្នឹងឯង។

ដានី: ខាងតាម៉ុក គេចូលមក?

ស៊ុន: បាទ កូនចៅតាម៉ុក ។

ដានី: កាលហ្នឹងប្រជាជននៅច្រើនអត់?

ស៊ុន: នៅច្រើន វាមិនសូវជាច្រើនប៉ុន្មានទេ ខ្ចាចបែកទៅនៅព្រៃជ្រូក ។

ដានី: ប្រហែលប៉ុន្មានពេលលោកពូចូលមកនៅនេះ?

ស៊ុន: កាលនោះប្រហែលជាមិនដល់១០០ទេដឹង ប្រហែលជា៥០-៦០គ្រួសារ ។

ដានី: ខស្សរាហ៍ចូលមក ឬយូរៗចូលមកម្ដងខាងខ្មែរក្រហម?

ស៊ុន: យូរៗចូលម្ដង ។

ដានី: ចុះខាងទាហាន ខាងរដ្ឋកម្ពុជា គេមានចូលមកដែលអត់?

ស៊ុន: ទាហានមកដែរ ជួនកាលក៏វៃគ្នាខ្លះ អត់ខ្លះ ។

ដានី: វៃគ្នាវៃក្នុងភូមិហ្នឹង?

ស៊ុន: បាទ វៃគ្នាតិចតួច ។

ដានី: ចុះខាងវៀតណាម?

ស៊ុន: អត់មានវៀតណាមទេកាលនោះ ។

ដានី: អត់មានវៀតណាមទេ?

ស៊ុន: វៀតណាមទៅហើយ ។

ដានី: វៀតណាមដកទៅហើយ?

ស៊ុន: បាទ ។

ដានី: អីចឹងមានតែទាហានរដ្ឋកម្ពុជា ហើយនិងទាហានតាម៉ុកវៃគ្នា?

ស៊ុន: បាទ ។

ដានី: ពេលដែលទាហានវៃគ្នា មិនមែនវៃក្នុងភូមិ វៃក្បែរភូមិ?

ស៊ុន: បាទ វៃក្បែរៗហ្នឹង ។

ដានី: ពេលដែលវៃគ្នាអីចឹង មានដូចថាត្រូវរបួសប្រជាជន ឬក៏ស្លាប់ដែលអត់?

ស៊ុន: មានស្លាប់ខ្លះ អត់ខ្លះ ខ្មែរក្រហមក៏មានស្លាប់ ។

ដានី: មានខ្មែរក្រហមស្លាប់ខ្លះដែរ?

ស៊ុន: បាទ ។

ដានី: តែលោកពូកាលហ្នឹងអត់មានចូលធ្វើខាងណា? ខាងទ័ពអីទៀតទេ?

ស៊ុន: អត់ទេ ព្រោះកាលហ្នឹងខ្ញុំពិការ មិនទាន់សះទេរបួសខ្ញុំ ខ្ញុំធ្វើតែស្រែតិចតួចអាចធ្វើបាន ។

ដានី៖ ក្នុងកោះកេរ្តិ៍ហ្នឹងខាងណាគេនៅ? មានទ័ពនៅដែលអត់?

ស៊ុន៖ កោះកេរ្តិ៍អត់ទេ កាលនោះមានតែប្រជាពលរដ្ឋយើងសព្វថ្ងៃ ។

ដានី៖ អត់មានទេណោះ?

ស៊ុន៖ បាទ ។

ដានី៖ គេវ៉ៃគ្នាមានដែលវ៉ៃក្បែរៗកោះកេរ្តិ៍ មានដែលបាញ់ត្រូវប្រាសាទដែលអត់?

ស៊ុន៖ អត់ទេ ។

ដានី៖ អត់មានត្រូវទេ?

ស៊ុន៖ បាទ ។

ដានី៖ ខាងខ្មែរក្រហមគេចូលមកច្រើនតែចូលមកសុំអង្ករ មានសុំអីទៀត?

ស៊ុន៖ សុំតែអង្ករ មាន់ ។

ដានី៖ យើងឲ្យដែរ?

ស៊ុន៖ ឲ្យ ដែលមិនឲ្យយើងប្រជាពលរដ្ឋ ។

ដានី៖ តែគេសុំយើងឲ្យហើយ?

ស៊ុន៖ បាទ ឲ្យហើយ ខ្មែរក្រហមជាបង ជាប្អូនខាងប្រពន្ធខ្ញុំ ។

ដានី៖ ខាងទាហាន ខាងរដ្ឋកម្ពុជាគេចូលមកមានសុំអង្ករ សុំមាន់អីចឹងដែរ?

ស៊ុន៖ ទាហានមិនដែលបានសុំទេ វាចាប់យកៗ ។

ដានី៖ ចាប់យកៗតែម្តង?

ស៊ុន៖ បាទ អត់មានសុំទេ មិនបាច់សុំទេ ។

ដានី៖ មានធ្វើបាបយើងដែរ?

ស៊ុន៖ ទេបើមិនបានគេចក៏ធ្វើបាប សំលុត ។

ដានី៖ ខាងទាហានរដ្ឋកម្ពុជាចូលមកចាប់យកៗតែម្តង បើយើងមិនគេចក៏ធ្វើបាបយើងដែរ?

ស៊ុន៖ បាទ ។

ដានី៖ ខាងខ្មែរក្រហមអត់អីទេ?

ស៊ុន៖ អត់អីទេ ។

ដានី៖ ខាងខ្មែរក្រហមដូចជាបង ដូចជាប្អូនវិញ?

ស៊ុន៖ បាទ ។

ដានី៖ ហើយខាងបងប្អូនប្រជាជនយើងមានចូលខាងខ្មែរក្រហមច្រើនទេ? ចូលធ្វើកងទ័ពខ្មែរក្រហម?

ស៊ុនៈ មានចូលខ្លះ ។

ដានីៈ មានចូលខ្លះៗដែរ?

ស៊ុនៈ បាទ ។

ដានីៈ កាលហ្នឹងប្រាសាទមានមនុស្ស មានប្រជាជនអីមកមើល ដូចថាភ្ញៀវទេសចរណ៍អីគេមកមើលប្រាសាទអីដែលអត់?

ស៊ុនៈ មិនដែលមានមកទេ ។

ដានីៈ កាលពេលសង្គ្រាមអត់ដែលមានមកទេ?

ស៊ុនៈ គេមិនហ៊ានមកទេ ទើបតែរំដោះ ផ្ដាច់ខ្លួនរួបរួមគ្នាហើយ ។

ដានីៈ ចុះក្នុងភូមិហ្នឹងមានគេដាក់មីនដែលអត់?

ស៊ុនៈ មានតាំ ដាក់ក្នុងភូមិ តែស៊ីម៉ាក់គេរាវអីអស់ ។

ដានីៈ ឥឡូវស៊ីម៉ាក់រាវអស់ហើយ?

ស៊ុនៈ បាទ ។

ដានីៈ កាលសម័យសង្គ្រាមមានដាក់ក្នុងភូមិដែរ?

ស៊ុនៈ មានដាក់ចោលខ្លះ ។

ដានីៈ ដាក់ចោល ដល់ពេលស៊ីម៉ាក់មករាវរកឃើញមីនច្រើនទេ?

ស៊ុនៈ បានច្រើន ។

ដានីៈ ដល់ឆ្នាំណាដែលលែងមានសង្គ្រាមតែម្ដង?

ស៊ុនៈ ឆ្នាំ២០០០គត់ អានោះស្រួលមែនទែនរហូតមកសព្វថ្ងៃ ដែលមានអង្គការអភិវឌ្ឍន៍មកជួយខ្លះៗដែរ ។

ដានីៈ ឆ្នាំ២០០០បានចប់សង្គ្រាមមែនទែន?

ស៊ុនៈ ចប់ឯករាជ្យរហូត ។

ដានីៈ ស៊ីម៉ាក់ចូលមករាវមីនឆ្នាំណាទៅ?

ស៊ុនៈ មកឆ្នាំ២០០០ដែរ តែខ្ញុំមិនដឹងថ្ងៃប៉ុន្មាន ខែប៉ុន្មានទេ ដូចភ្នាក់ងារសមត្ថកិច្ចគេមកសេរីហ្នឹងដែរ ដែលមកកាន់កាប់អាជ្ញាធរអប្សរាយើងសព្វថ្ងៃ សមត្ថកិច្ចប៉ូលីស ។

ដានីៈ ខាងអប្សរាគេមកឆ្នាំ២០០០ដែរ?

ស៊ុនៈ បាទ ។

ដានីៈ ប្រជាជនយើងដូចថាម៉េចដែរ បើយើងប្រៀបធៀបមើលកាលពីសម័យសង្គ្រាមហើយក្រោយមកពីសម័យសង្គ្រាមខុសប្លែកគ្នាម៉េចទៅ?

ស៊ិនៈ ខុសប្លែកច្រើន ព្រោះសម័យសង្គ្រាមមានការលំបាកនិងការអត់ឃ្លាន បាយហូបមិនច្រើន កាលសម័យសង្គ្រាមមានការលំបាកនឹងគ្រោះថ្នាក់គ្រាប់រំសេវអី ។

ដានីៈ កាលហ្នឹងដូចថាជីវភាពរស់នៅវិញម៉េចដែរខុសគ្នា កាលសម័យសង្គ្រាមហើយមកដល់ឥឡូវ?

ស៊ិនៈ សម័យសង្គ្រាមជីវភាពលំបាកនឹងកាលសង្គ្រាម ការអត់អីហូប ។

ដានីៈ ឥឡូវធូរធារជាង?

ស៊ិនៈ សព្វថ្ងៃធូរធារសប្បាយនឹងការដើរហើរ ការធ្វើស្រែចំការក៏ស្រួល បានស្រូវក៏យើងលក់ ។

ដានីៈ ប្រាសាទអីមានភ្ញៀវទេសចរណ៍មក?

ស៊ិនៈ មកកុះករច្រើន ភ្ញៀវបរទេស ។

ដានីៈ ភ្ញៀវបរទេសមកច្រើន?

ស៊ិនៈ បាទ មកច្រើន ។

ដានីៈ អ្នកស្រុក អ្នកភូមិដែលបានទទួលផលប្រយោជន៍អីពីប្រាសាទខ្លះនៅ?

ស៊ិនៈ បានខ្លះ អំណោយគេជួយ ថ្ងៃមុនគេជួយសារុង ថ្នាំពេទ្យ ។

ដានីៈ ពីណាគេជួយ?

ស៊ិនៈ អង្គការអីគេទេ ខ្ញុំអត់សូវស្គាល់ គេមកធ្វើបុណ្យ ។

ដានីៈ ដូចថាកូនចៅអ្នកស្រុក អ្នកភូមិមានណាធ្វើការដើម្បីបំរើប្រាសាទ ហើយបានប្រាក់ខែដែលភ្ញៀវទេសចរណ៍ចូលមកដូចថាយើងបានអីនៅប្រជាជន?

ស៊ិនៈ ធ្វើកម្មករបោសសំអាតប្រាសាទ យាម បានប្រាក់ខែមួយខែ២០ដុល្លា ៨ម៉ឺន ខាងកម្មករជិះស្មៅបានមួយខែ៣០ម៉ឺន មួយថ្ងៃ១ម៉ឺន ។

ដានីៈ លោកពូមានលឺគំរោងគេមានមកអភិវឌ្ឍន៍ប្រាសាទ?

ស៊ិនៈ អត់ដឹង អត់ដែលលឺ ។

ដានីៈ អត់ដែលលឺទេ?

ស៊ិនៈ បាទ ។

ដានីៈ លោកពូមានចង់ឲ្យគេមកអភិវឌ្ឍន៍ មកអភិរក្សប្រាសាទដែលអត់?

ស៊ិនៈ ចង់ឲ្យបានអង្គការណាជួយពួកខ្ញុំជួយអរ ព្រោះប្រាសាទការន់តែបាក់បែកអស់ហើយ ថ្មរលំខ្លះ ។

ដានីៈ ហេតុអីលោកពូចង់ឲ្យគេមកអភិវឌ្ឍន៍?

ស៊ុនៈ ចង់មកដើម្បីឲ្យរីកចំរើននៅក្នុងតំបន់អប្សរា ហើយនឹងប្រទេសដែលភ្ញៀវទេសចរណ៍មកច្រើន ដើម្បីថាមានលុយកាក់ចូលមកក្នុងប្រទេសយើងច្រើន ស្រុកខេត្ត ។

ដានីៈ លោកពូខ្ញុំអរគុណលោកពូច្រើន ។

ស៊ុនៈ បាទ ជំរាបលា ។

ចប់